**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ......៦០០..........អពដ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០១៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តពង្រឹងការអនុវត្តរបបស្វ័យប្រកាស(របបពិត)

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនលោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ ម្ចាស់សហគ្រាស-អាជីវកម្មដ្ឋាន និងសាធារណជនទូទៅទាំងអស់ជ្រាបថា ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការពង្រឹងនិងបញ្ចូលសហគ្រាស-អាជីវកម្មដ្ឋានពីរបបម៉ៅការ ឲ្យបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបស្វ័យប្រកាស នៅតែត្រូវបានបន្តអនុវត្តដោយគ្មានងាករេនិងខ្ជាប់ខ្ជួនជាប្រចាំ ដូចមានក្នុងទិសដៅនិងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានពន្ធដារ ។ អគ្គនាយកដ្ឋានពន្ធដារ ពុំមានគោលការណ៍ណាមួយអនុញ្ញាតឲ្យសហគ្រាស-អាជីវកម្មដ្ឋានដែលបាននិងកំពុងបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបស្វ័យប្រកាសរួចហើយ ឲ្យទៅបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបម៉ៅការវិញដោយគ្មានការវាយតម្លៃច្បាស់លាស់ទេ ។

ក្នុងករណី ពិនិត្យឃើញមានសហគ្រាស-អាជីវកម្មដ្ឋានដ៏ទៃដែលមានទំហំអាជីវកម្មប៉ុនគ្នា ឬប្រហាក់ប្រហែលគ្នា និងមានកម្មវត្ថុអាជីវកម្មដូចគ្នា ប៉ុន្តែអាចបន្តបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបម៉ៅការបានជាកត្តានាំឲ្យមានអសមភាពក្នុងការប្រកួតប្រជែងលើទីផ្សារ ម្ចាស់សហគ្រាស-អាជីវកម្មដ្ឋានដែលកំពុងបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបស្វ័យប្រកាស ឬសាធារណជនទូទៅទាំងអស់ អាចជូនដំណឹងមកអគ្គនាយកដ្ឋានពន្ធដារ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់នូវ ឈ្មោះ និងអាសយដ្ឋានសហគ្រាស-អាជីវកម្មដ្ឋានកំពុងប្រកបអាជីវកម្មតាមរបបម៉ៅការនោះ និងភ្ជាប់មកជាមួយនូវសក្ខីកម្មផ្សេងៗផងបើមាន ។ លិខិតផ្តល់ដំណឹងត្រូវបញ្ជូនមកអគ្គនាយកដ្ឋានពន្ធដារដោយផ្ទាល់ ឬស្កេន (scan) រួចផ្ញើមកអ៊ីម៉ែលនេះ gdt@tax.gov.kh នៃអគ្គនាយកដ្ឋានពន្ធដារ ដោយពុំចាំបាច់បញ្ចេញឈ្មោះរបស់ខ្លួនឡើយ ។ អគ្គនាយកដ្ឋានពន្ធដារ នឹងចាត់បញ្ជូនមន្ត្រីទៅពិនិត្យបញ្ចូលសហគ្រាស-អាជីវកម្មដ្ឋានក្នុងរបបម៉ៅការនោះ ឲ្យបំពេញកាតព្វកិច្ចសារពើពន្ធតាមរបបស្វ័យប្រកាស ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា សាខាពន្ធដារខេត្ត-ខណ្ឌ លោក-លោកស្រីជាម្ចាស់សហគ្រាស-អាជីវកម្មដ្ឋាន និងសាធារណជនទូទៅទាំងអស់ពិតជាយកចិត្តទុកដាក់ និងសហការអនុវត្តន៍តាមខ្លឹមសារនៃសារលិខិតនេះឲ្យមានប្រសិទ្ធភាព ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

Collection by VCAT Professional Consultant